ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(២៨)

Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(28)

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jul-2013, 16:41
CMS/CFO: Sann Rada

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Judge Florence Ndepele Mwachande MUMBA**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

---

# ដីកាទាក់ទងនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ

---

<u>**សហព្រះរាជអាជ្ញា**</u>

ជា លាង
Andrew CAYLEY

<u>**សហមេធាវីជនជាប់ចោទ នួន ជា**</u>

សុន អរុណ
Victor KOPPE

<u>**ជនជាប់ចោទ**</u>

<u>**សហមេធាវីជនជាប់ចោទ ខៀវ សំផន**</u>

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Elisabeth SIMONNEAU FORT

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

**យើង គង់ ស្រ៊ីម** ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក"),

**រំលឹកថា** នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពលើ ដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយនៃសំណុំរឿង ០០២ ដោយពុំបានធ្វើឱ្យប៉ះពាល់ដល់ ការវាយតម្លៃសាជាថ្មីរបស់អង្គជំនុំជម្រះលើសំណុំរឿង ០០២[1]។

**រំលឹកបន្ថែមទៀត**ថា នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល ប្រកាសថា "ក្នុងស្ថានការណ៍នៃការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ អង្គជំនុំជម្រះពិចារណាឃើញថា អ.វ.ត.ក គប្បីស្វែងរកលទ្ធភាពបង្កើតក្រុមប្រឹក្សាជំនុំជម្រះមួយផ្សេងទៀត នៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បី គាំទ្រការជំនុំជម្រះឱ្យបានទាន់ពេលលើបទចោទសេសសល់នៃសំណុំរឿង០០២";[2]

**កត់សម្គាល់**ថា នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូង សម្រេចបំបែកសំណុំរឿង ០០២ ជាថ្មីម្តងទៀត[3] ហើយ

**រំលឹក**ថា នៅថ្ងៃទី ២៣ ខែ កក្កា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ស្ថានភាពនៃដីកាបំបែកជាថ្មីនៃសំណុំរឿង ០០២ មានលក្ខណៈសំខាន់ ដែលតម្រូវឱ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៅក្នុងអង្គជំនុំជម្រះ ដើម្បីធានាបានថា សំណុំរឿង ០០២/០២ អាចចាប់ផ្តើមបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន បន្ទាប់ពីបិទកិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១[4]

---

[1] សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ ឯកសារលេខ E163/5/1/13, ថ្ងៃទី ០៨ ខែ កម្ភៈ ឆ្នាំ ២០១៣ ("សេចក្តីសម្រេចរបស់អជតក"), កថាខណ្ឌ ៤៩ ដល់ ៥០ , ៥២។

[2] សេចក្តីសម្រេចរបស់អជតក, កថាខណ្ឌ ៥១។

[3] សេចក្តីសម្រេចស្តីពីដីកាបំបែកសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារលេខ, E284, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។

[4] សេចក្តីសង្ខេបនៃសំអាងហេតុៈ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើកទីពីរ ឯកសារលេខ E284/4/7,ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១១។

សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ/អ.ជ.ត.ក (២៨)

ឯកសារលេខ E284/4/7/1

**ហេតុដូច្នេះ** បង្គាប់ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ស្វែងរកភ្លាមៗលទ្ធភាពក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ដែលមានចៅក្រមជាតិ និងអន្តរជាតិ នៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីស្តាប់ និងជំនុំជម្រះសំណុំរឿង ០០២/០២។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**